យក់គីនមាសស្នេហ៍បងប្រាថ្នា
សព្វថ្ងៃសាកល្បងចិត្តស្ងួនភ្ងារ
យកស្រីជីវ៉ាជាភរិយា
តើយើងត្រូវគ្នាប៉ុន្មានដែរ។

បងនៅឆ្ងាយអូនឯស្រុកគេ
សង្ឃឹមអនាគតបាននៅក្បែរ
រៀនមិនទំនេរខ្មែរមិនល្ហែរ
កៀកកើយថ្នមថែរស្នេហ៍អោយគង់។

យើងឆ្ងាយគ្នាពិតតែចិត្តពៅ
ភ្ជាប់ពាក្យថ្ងៃណាបងត្រៀមប្រុង
និងបងដក់ជ្រៅព្រមទាំងស្រុង
មិនអោយឆោមយុងអូនព្រួយភ័យ។

ស្នេហ៍យើងឧត្តមសមប្រាថ្នា
រលឹករកគ្នាតែសព្វថ្ងៃ
ស្នេហ៍បរិសុទ្ធថ្លាមានអត្ថន័យ
ឆ្ងាយយ៉ាងណាក្ដីគង់ជិតគ្នា។

យក់គីនអូនល្អគ្រប់ម្លេះទេ
ចរិយាសម្បត្តិក៏សមជា
មុខមានមន់ស្នេហ៍ស្រស់សោភារ
ស្ត្រីខ្មែរមានងាររថ្កើងគ្រួសារ។

សម្ដីស្រីពោលក៏ពិរោះ
ចេះស្គាល់បុណ្យបាបចិត្តជ្រះថ្លារ
សក្ដិសមកិត្តិយសនិងបញ្ញា
កត្តញ្ញូរធម៌តាសមជាកូន។